# ប្រាសាទព្រះស្រី

ប្រាសាទព្រះស្រី មានទីតាំងស្ថិតនៅភូមិប្រាសាទ ឃុំដារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដែលស្ថិតនៅភាគអាគ្នេយ៍ប្រាសាទសក្ខចម្ងាយប្រមាណ ២គីឡូម៉ែត្រ និងស្ថិតនៅខាងកើតភ្នំទូកមាស។ កាលពីរវាងដើមសតវត្សរ៍ទី២០ អ្នកសិក្សាស្រាវជ្រាវមកពីតំបន់អឺរ៉ុបធ្លាប់មកសិក្សាអំពីប្រាសាទព្រះស្រីជាច្រើនដងរួចមកហើយ ដែលក្នុងនោះអ្នកសិក្សាដំបូងគេ ជាអ្នកស្រាវជ្រាវជនជាតិបារាំងមានឈ្មោះថា Etienne Aymonier ក្នុងឆ្នាំ១៩០១ និងមួយឆ្នាំក្រោយមកលោក Lunet De Lajonquire ក៏បានមកសិក្សានិងចុះបញ្ជីប្រាសាទនេះបន្ត។ ក្រោយមកទៀត នៅក្នុងឆ្នាំ១៩២៧ លោក Henri Parmentier បានសិក្សាអំពីស្ថាបត្យកម្ម និងគូរប្លង់ប្រាសាទនេះលម្អិត ចុះផ្សាយនៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា *“L’art Khmere Primitif”*។ ក្រោយមកនៅក្នុងឆ្នាំ ១៩៧១ លោកស្រី Mireille Bénisti ក៏មកសិក្សាបន្ថែម ដើម្បីកំណត់អាយុកាលរបស់ប្រាសាទ ហើយជាលទ្ធផលលោកស្រី បានកំណត់ប្រាសាទព្រះស្រីចូលក្នុងសិល្បៈរចនាបថចុងព្រៃក្មេង ដើមរចនាបថកំពង់ព្រះ ពោល គឺនៅរវាងពាក់កណ្ដាលស.វ.ទី៧ ដើមស.វ.ទី៨។ ជាទូទៅ អ្នកស្រុកច្រើនភ្ជាប់ឈ្មោះប្រាសាទនេះជាមួយរឿងព្រេងដែលដូចទៅនឹងរឿងព្រេងភ្នំប្រុសភ្នំស្រី ខេត្តកំពង់ចាម ដែលយើងធ្លាប់ស្ដាប់ឮច្រើនតំបន់ផ្សេងៗគ្នាដែរ។ ប៉ុន្តែសម្រាប់លោក Etienne Aymonier យល់ថា ឈ្មោះថា “**ព្រះស្រី**” នេះ អាចសំដៅដល់ទេពស្រីមួយអង្គដែលជាតួអង្គមហេសីរបស់ព្រះវិស្ណុ ពោល គឺព្រះនាងលក្ស្មី។[១] ឈ្មោះនេះ មានលក្ខណៈស៊ីគ្នានឹងគំនិតដែលថា ប្រាសាទដែលមានតួប៉មពីរច្រើនតែប្រាសាទដែលឧទ្ទិសដល់ព្រះវិស្ណុ ក្នុងព្រហ្មញ្ញសាសនា ដូចលោក សុខ កែវសុវណ្ណារ៉ា ធ្លាប់បានលើកឡើងដូច្នោះដែរ ដ្បិតថាប្រាសាទព្រះស្រីក៏មានតួប៉មពីរដូចគ្នាដែរ (តួប៉មមួយតម្កល់ព្រះវិស្ណុ និងតួប៉មមួយទៀតតម្កល់ព្រះនាងលក្ស្មី)។[២]

ប្រាសាទព្រះស្រី មានតួប៉មចំនួនបី សាងឡើងពីឥដ្ឋ ដែលក្នុងនោះតួប៉មពីររត់ជួរទន្ទឹមគ្នាពីជើងទៅត្បូងបែរមុខទៅទិសខាងកើត ហើយតួប៉មមួយទៀតស្ថិតនៅខាងលិចតួប៉មទីមួយនិងបែរមុខទៅទិសខាងលិចផង។ ប៉ុន្តែសព្វថ្ងៃក្នុងចំណោមតួប៉មទាំងបីនេះ មានតែតួប៉មទី១ប៉ុណ្ណោះដែលនៅឈរមានរូបរាង (តួប៉មពីរទៀតបានបាក់រលំអស់ទៅហើយ)។ តួប៉មដែលនៅសល់សព្វថ្ងៃនៅមានរូបរាងល្អប្រសើរ ដែលមានរាងបួនជ្រុងទ្រវែង និងមានក្បាច់លម្អយ៉ាងប្រណិតស្រដៀង

---

[១] Aymonier 1900.

[២] សុខ កែវសុវណ្ណារ៉ា ២០២០។

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ប្រាសាទកំពង់ព្រះ នៅស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង (រូបលេខ១-២)។ ប្រាសាទនេះសង់ឡើងក្នុងទម្រង់យកលំនាំតាមសំណង់ប្រាសាទនៃសិល្បៈឥណ្ឌាខាងជើង (វលភី) និងខាងត្បូង (សាលា) ពោល គឺមានរូបរាងជាដំបូលខាងលើបង្អស់មានរាងកោងដូចទូក ហើយពេលខ្វះមានដំបូលច្រើនជាន់ដែលកើតចេញពីការចម្លងទម្រង់ផ្នែកខាងក្រោមឱ្យរួមតូចបន្តុបលើគ្នាជាច្រើនថ្នាក់។[៣] សព្វថ្ងៃយើងពិបាកមើលដំបូលប្រាសាទព្រះស្រីឱ្យឃើញជារាងដូចទូកណាស់ ដ្បិតផ្នែកឥដ្ឋដំបូលមានការជ្រុះធ្លាក់មកក្រោមដោយអន្ទើ ប៉ុន្តែប្រសិនយើងមើលទៅប្លង់ដែលគូរដោយលោក Henri Parmentier យើងនឹងឃើញថាដំបូលខាងលើបង្អស់ស្រដៀងទូកដូចទម្រង់ប្រាសាទបែបវលភីនៅឥណ្ឌាខាងជើងយ៉ាងពិតប្រាកដ (រូបលេខ៣)។[៤] លក្ខណៈបែបនេះ យើងធ្លាប់ឃើញនៅប្រាសាទជាច្រើន ដូចជា ប្រាសាទភូមិប្រាសាទ ប្រាសាទជ្រៃ ។ល។

បើមើលពីការលម្អនៅប្រាសាទព្រះស្រីវិញ យើងឃើញសិល្បករនិយមឆ្លាក់ក្បាច់រុក្ខជាតិតាមផ្នែកជាច្រើននៃប្រាសាទ ជាពិសេសនៅតាមសសរផ្អោប ហើយបើនៅលើជញ្ជាំងវិញយើងឃើញគេឆ្លាក់រូបវិមានអណ្ដែត ដែលជាសិល្បៈដ៏ពេញនិយមនៅតំបន់សំបូរព្រៃគុក ។ ប៉ុន្តែ ចម្លាក់វិមានអណ្ដែតនៅប្រាសាទព្រះស្រី (រូបលេខ៤) មានលក្ខណៈខុសគ្នាខ្លាំងពីចម្លាក់វិមានអណ្ដែតនៅតំបន់សំបូរព្រៃគុក ហើយមានលក្ខណៈស្រដៀងវិមានអណ្ដែតប្រាសាទអំពិលរលំ ខេត្តកំពង់ធំ និងប្រាសាទព្រះធាតុសម្ដី ខេត្តត្បូងឃ្មុំ។[៥] ចំណែក ផ្ដែរទ្វារវិញ សិល្បករលម្អគ្រប់ជ្រុងទាំងបួន (ទាំងទ្វារចូលខាងកើត និងទ្វារបញ្ឆោតទាំងបី) ប៉ុន្តែមិនមានលក្ខណៈដូចគ្នានោះឡើយ។ ដូចយើងឃើញជាក់ស្ដែង ផ្ដែរទ្វារខាងកើតនិងខាងជើង លោកស្រី Mireille Bénisti យល់ថា មានទម្រង់ជាសិល្បៈរចនាបថព្រៃក្មេង ហើយផ្ដែរទ្វារខាងត្បូងនិងខាងលិច (រូបលេខ៥) លោកស្រីយល់ថា មានទម្រង់ជាសិល្បៈចុងរចនាបថព្រៃក្មេង (រូបលេខ៦) ដើមរចនាបថកំពង់ព្រះ ពោល គឺចុងស.វ.ទី៧ ដើមស.វ.ទី៨។ ផ្ដែរទ្វារប្រាសាទព្រះស្រី មានលក្ខណៈជាទូទៅស្រដៀងផ្ដែរទ្វារប្រាសាទសក្កដែលស្ថិតនៅមិនឆ្ងាយពីប្រាសាទព្រះស្រីដែរ។

យើងមិនអាចដឹងច្រើនអំពីសាវតារប្រាសាទព្រះស្រីច្រើនឡើយ ដ្បិតប្រាសាទនេះពុំមានបន្សល់សិលាចារឹកឱ្យយើងសិក្សាឡើយ ប៉ុន្តែលោក Etienne Aymonier ធ្លាប់អះអាងថា នៅឆ្នាំ ១៨៧៩ មានសិលាចារឹកប្រមាណ១០-១៥បន្ទាត់ជាងចារនៅលើមេទ្វារ តែបានរលុបវិញនៅឆ្នាំ

---

[៣] ឡេង ស៊ីវ៉ង់ ២០២២។

[៤] Parmentier 1927.

[៥] Bénisti 1971.

*១៨៨២[1]។ ម្ល៉ោះហើយ យើងមិនមានទិន្នន័យសម្រាប់សិក្សាបានទេ។ ប៉ុន្តែ បើយើងក្រឡេកមើលរូបថតចាស់ដែលថតនៅសម័យអាណានិគមបារាំង ក្នុងរវាងឆ្នាំ១៩៣៨ កាលពីតួប៉មប្រាសាទព្រះស្រីមួយទៀតនៅឈរនៅឡើយ (រូបលេខ៧) យើងអាចសន្និដ្ឋានថា ប្រាសាទទាំងពីរដែលនៅទន្ទឹមគ្នានេះ អាចសង់ឡើងនៅសម័យកាលខុសគ្នា ព្រោះការលម្អនៅលើជញ្ជាំងជាទូទៅរបស់តួប៉មដែលបានបាក់រលំនោះ មិនមានលក្ខណៈដូចគ្នាជាមួយប្រាសាទដែលនៅឈរឡើយ។ ហេតុដូច្នេះហើយ ប្រាសាទដែលនៅទន្ទឹមគ្នាជាមួយប្រាសាទនៅឈរសព្វថ្ងៃនេះ អាចជាប្រាសាទដែលសង់បន្ថែមនៅសម័យអង្គរ ក្នុងរវាងស.វ.ទី១០ ព្រោះបើយើងមើលប្រាសាទនៅជុំវិញប្រាសាទព្រះស្រី ច្រើនតែជាសំណង់ប្រាសាទមានតួប៉មពីរដែលឧទ្ទិសដល់ព្រះវិស្ណុ (តួប៉មមួយតម្កល់ទេពវិស្ណុ និងមួយទៀតតម្កល់ទេពស្រីលក្ស្មី) សង់ក្នុងរវាងស.វ.ទី១០ ឧទាហរណ៍ ប្រាសាទថ្មមប្តី និងប្រាសាទភ្នំពណ្ណរាយជាដើម។*

*ជារួមមក ប្រាសាទព្រះស្រី ទំនងជាបូជនីយដ្ឋានដែលឧទ្ទិសដល់ព្រហ្មញ្ញសាសនា ហើយអាចនិកាយព្រះវិស្ណុ ដែលចាប់ផ្តើមឡើងដំបូងនៅចុងស.វ.ទី៧ ដើមស.វ.ទី៨ នៃរចនាបថកំពង់ព្រះ និងអាចសាងសង់បន្ថែមនៅសម័យអង្គរ (ទំនងស.វ.ទី១០)។ ប្រាសាទនេះសាងសង់ឡើងក្នុងទម្រង់ជាស្ថាបត្យកម្មដែលទទួលឥទ្ធិពលសិល្បៈឥណ្ឌា ដូចប្រាសាទផ្សេងៗទៀតនៅកម្ពុជាក្នុងសម័យកាលស្រដៀងគ្នាដែរ តួយ៉ាងដូចជា ប្រាសាទជ្រៃ ប្រាសាទភូមិប្រាសាទ ប្រាសាទសក្ក ប្រាសាទកំពង់ព្រះជាដើម៕*

## ឯកសារយោង


***សុខ កែវសុវណ្ណារ៉ា***

*២០២០, "ទស្សនៈថ្មីលើប្រាសាទព្រះវិស្ណុ", អត្ថបទក្នុង AMS Khmer Civilization, សៀមរាប។*

***ឡេង ស៊ីវ៉ង់***

*២០២២, "ប្រាសាទបែបវលភីក្នុងសិល្បៈឥណ្ឌា និងសិល្បៈខ្មែរ", អត្ថបទក្នុង AMS Khmer Civilization, សៀមរាប។*

**Aymonier, Etienne**

1900, *Le Cambodge: Le Royaum Actuel*. Paris. Ernest Leroux.

**Bénisti, Mireille**

1971, “Recherches sur le premier art khmer, III. Aux confins des styles de Prei Kmeng et de Kampong Preah ”, *Arts Asiatiques*, Tome 23, Paris.

**Lunet De Lajonquière**

1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris.


[1] Aymonier 1900.

**Parmentier, Henri**
1927, *“L’Art Khmér Primitif”*, Tome I, Paris.



*រូបលេខ១៖ ប្រាសាទព្រះស្រី (មើលពីមុខអាគ្នេយ៍)*អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៖ ប្រាសាទព្រះស្រី (មើលពីមុខពាយព្យ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣៖ ក្បាច់លម្អផ្នែកកំពូលប្រាសាទព្រះស្រី មានលំនាំតាមប្រាសាទបែបវលភីនៃសិល្បៈឥណ្ឌាខាងជើង

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៨៖ ចម្លាក់វិមានអណ្តែតប្រាសាទព្រះស្រី



រូបលេខ៩៖ ផ្តែរទ្វារខាងកើតប្រាសាទព្រះស្រី

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៦៖ ផ្តែរទ្វារខាងជើងប្រាសាទព្រះស្រី




រូបលេខ៧៖ ប្រាសាទព្រះស្រី ថតនៅឆ្នាំ១៩៣៨ (ប្រភព៖ EFEO_CAM01397)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី